ពេលខ្លះ នារីម្នាក់នោះសម្លឹងមកខ្ញុំដោយលួចលាក់ អាថ៌កំបាំង តែក៏មានពេលខ្លះនាងលួចមើលខ្ញុំដោយភ្លេចខ្លួន គឺមើលមកពីចម្ងាយ។

ក្រោយមកទៀត ខ្ញុំសម្គាល់បានទេ នាងតែងតែលបសម្លឹងមើលមុខខ្ញុំយូរៗ កាន់តែយូរឡើងៗ ប្រសិនបើខ្ញុំបន្លំធ្វើមិនដឹងខ្លួន។

បន្ទាប់មក ពេលខ្ញុំក្រឡេកទៅវិញរឹបដើម្បីចាប់ខ្សែភ្នែក«ចោរ»របស់នាង នាងក៏ធ្វើសកម្មភាពបន្លប់ចេញយ៉ាងរហ័សវិញដូចគ្នា។

ទោះយ៉ាងណាជារឿយៗថ្ពាល់នាងហាក់ដូចជាឡើងក្រហមពេលខ្ញុំឈានចូលទៅ។

«ហេតុអ្វី ? » ខ្ញុំសួរនាង។

«នៅមិននៅមកសួរកំបុតមានន័យថាម៉េច ?» នាងឆ្លើយអ៊ីចឹង ធ្វើដូចក្មេងមិនយល់រឿង។

«ហេតុអីមើលខ្ញុំ!»

«មានភស្តុតាងអត់ ?»

«ថាទេក៏បាន តែកុហកបេះដូងម៉េចបាន ?»

នេះហើយរាល់ពេលដែលខ្ញុំព្យាយាមចូលទៅជិតនាង នាងធ្វើហាក់មិនស្រួល ? មិនសុខ មានសម្ពាធ មានការលំបាកក្នុងការត្រង់ទៅត្រង់មកជាមួយគ្នា។

«ធ្វើមើលតែខ្លួនឯងហ្នឹងស្អាតផុតលេខអ៊ីចឹង!»

នាងរអ៊ូថាឱ្យខ្ញុំចាំៗហើយដើរចេញ ។ ខ្ញុំនៅបែរខ្នងញញឹមតែម្នាក់ឯង។

ខ្ញុំអាយុ២៦ឆ្នាំហើយ។ មនុស្សស្រីដែលលបមើលខ្ញុំក៏មានមិនក្រោម១០នាក់ដែរ។ រឿងខុសគ្នាគឺ ពួកគេខ្លះនៅពេលយើងចាប់ការសម្លឹងរបស់ នាងបាន នាងហាក់ដូចជាខ្មាស់អៀន ខ្លះទៀតចាក់បណ្ដោយឱ្យយើងដឹងថានាងមានចិត្តតែម្ដង ចំណែកអ្នកប្រកែកនិងធ្វើឡូយដូចគេម្នាក់នេះខ្ញុំទើបតែជួបទេ ។

«ឈ្លោះជាមួយម៉ានីទៀតហើយ ?»

គ្នាខ្ញុំម្នាក់នេះគេឈ្មោះបញ្ញា គេមកសួរក្នុងនាមជាមិត្តដែលក៏ជាអ្នកដឹងរឿងបេះដូងខ្ញុំកន្លងមកគ្រប់យ៉ាង ។ បញ្ញាក្រៅពីជាក្មេងជិតខាង និងបានរៀនជាមួយគ្នាតាំងពីបឋមមកពេលនេះមកធ្វើការនៅកន្លែងតែមួយទៀត។ គេតាមសួរខ្ញុំពេលឃើញអានីចាកចេញពីទីនេះទៅរ៉ុយ។

ខ្ញុំមិនឆ្លើយអ្វីព្រោះមិនចង់និយាយ។ រឿងលើកនេះមិនចង់ប្រាប់បញ្ញាសោះ ព្រោះទាំងបីនាក់នៅធ្វើការជាមួយគ្នារាល់ថ្ងៃ តែត្រូវបញ្ញាថាមកទៀតមិនព្រមបង្អង់ទេ៖

«ត្រូវគេបដិសេធ?»

ខ្ញុំនៅតែមិនមាត់ព្រោះដឹងថា អាចមកពីខ្ញុំប្រញាប់ពេក ធ្វើឱ្យនាងមានអារម្មណ៍មិនស្រួលពេលដែលព្យាយាមចូលទៅជិតនាង។

ពេលខ្លះក៏មិនយល់ថា ហេតុអ្វីនៅឆ្ងាយលបមើលយើង ពេលមកក្បែរគេចចោលយើង?មនុស្សស្រី! ខ្ញុំធុញ នឹងជីវភាពញ៉ែស្រីណាស់ បន្លាយពេក និងពិបាកយល់ និយាយរួមឈឺក្បាល!

«ទៅធ្វើការ!!! ទំនេរចង់ដឹងរឿងអញណាស់!»

ខ្ញុំថាហើយវាយស្មាបញ្ញាមួយសំណុំឯកសារទើបចាកចោលមិត្តឱ្យនៅឈរបន្តផុងកាហ្វេទៀតចុះ។ ទោះយ៉ាងណា ខ្ញុំនៅតែបន្តSearchពីរឿងម៉ានី។ google ប្រាប់មកថា ពេលណាមនុស្សស្រីលបសំឡឹងមើលមកយើងជាសម្ងាត់ អាចមានន័យថា គេកំពុងពិនិត្យមើលចំណុចសម័យនេះទៅហើយ ការចែចង់មិនគួររំពឹងធ្វើដោយសម្ងាត់ ឬពីភាគីតែម្ខាងទៀតឯណានាំតែយល់ខុស។ រឿងអានីនិងខ្ញុំ មិនរាប់ថាជាការចែចង់នោះទេ ព្រោះការចែចង់ពិតប្រាកដតែងតែពាក់ព័ន្ធនឹងមនុស្សពីរនាក់ ប៉ុន្តែការក្រឡេកមើលដោយសម្ងាត់របស់អាចមានពាក់ព័ន្ធនិងមនុស្សតែម្នាក់ប៉ុណ្ណោះគឺខ្លួននាងថែមទាំងនាងមិនចង់ឱ្យខ្ញុំដឹងទៀត។

នៅកន្លែងខ្ញុំមានបុគ្គលិកស្រីដ៏ស្អាតម្នាក់ឈ្មោះ តា។ សុជាតាទើបនឹងចូលថ្មីតែរួសរាយ និងសក់វែងរលោងប្រុសៗជ្រួលជ្រើមគ្រប់ផ្នែក ពិសេសកម្លោះៗ។ ក្នុងនោះ ខ្ញុំក៏មិនមែនសត្វចម្លែកដែរ។

«ណេង នេះគេផ្ញើមក!»

សុជាតាធ្វើការនៅផ្នែកទទួលភ្ញៀវ ។ ខ្ញុំតាមញញឹមដាក់នាងយូរហើយ តែនាងមិនដែលឃើញញញឹមតបមក

សោះ ទើបតែថ្ងៃនេះនិយាយរកខ្ញុំជាលើកដំបូង ស្គាល់ទាំងឈ្មោះខ្ញុំច្បាស់ទៀត។

ខ្ញុំទទួលដែលគេផ្ញើមកនោះទាំងមិនរវល់បញ្ជើ ចិត្តចង់តែចែចង់នាង។

«ជាការអរគុណ សុំប៉ាវកាហ្វេបានអត់?!»

នាងនៅទីទើរហើយងាកមកវិញ ធ្វើជាសួរៈ

«និយាយ...ជាមួយខ្ញុំហ្អែន ?!»

«មានអ្នកណានៅហ្នឹងទៀត ?»ខ្ញុំតបដោយញញឹម។

«ប៉ាវកាហ្វេហ្អី? អឺ....អត់ញ៉ាំផង.....អត់ចេះញ៉ាំទេកាហ្វេ!»

នាងងាកទៅធ្វើការតែខ្ញុំដឹងច្បាស់ថានាងនឹងគិតពីខ្ញុំពេលនៅម្នាក់ឯង។

ជាធម្មតា លាក់ការសម្ងាត់នៃចិត្តប្រតិព័ទ្ធមិនដែលជួយជំរុញទំនាក់ទំនងស្នេហាឱ្យរីកចម្រើនទៅមុខនោះទេ ខ្ញុំមិនមែនជាប្រភេទមនុស្សលាក់បាំងអារម្មណ៍ស្នេហ៍ទុកជា អាថ៌កំបាំងឡើយ ព្រោះតែងយល់ថា ទំនាក់ទំនងរវាងមនុស្សពីនាក់នឹងកាន់តែល្អឡើងៗប្រសិនបើអារម្មណ៍ចំពោះភាគីទាំងសងខាងត្រូវបានបង្ហាញច្បាស់ៗ។

«ឮគេថាអ្អែងញ៉ែអាតា ?»

បញ្ញាតាមប្រដញសួរខ្ញុំ ឯខ្ញុំវិញដើរចេញធ្វើមិនឮមិនឆ្លើយឆ្លងអ្វីទាំងអស់។

«ចុះម៉ានីអ្ហុះ ?»

ភ្លាមនោះខ្ញុំនឹកឃើញដល់វ៉ាក់អឺនាងកាលពីព្រឹកពេលចុះជណ្ដើរ។ ភ្នែកនាងម្ដងទៀតហាក់ដូចមានការលាក់លៀមសម្លឹងមកខ្ញុំហើយគេចេញដដែលៗ។

ប៉ុន្មានថ្ងៃនេះ រវល់ជ្រួលជាមួយអ្នកឯទៀតរឿងបុគ្គលិកចូលថ្មីចង់ភ្លេចរឿងតាមចាប់ដានអ្នកលួចមើលខ្ញុំ។ កុំតែបានបញ្ញាជួយរំឮក។

ភ្លាមនោះខ្ញុំបង្វែរទិសដៅដើរទៅកាត់កន្លែងតុធ្វើការរបស់គេដែលនៅជាន់ខុសពីខ្ញុំ។

តាមរយៈកញ្ចក់របាំងផ្សេងៗ ខ្ញុំឃើញម៉ានីចោលខ្សែភ្នែកមកមើលខ្ញុំពីក្រោយខ្នងទៀត។ ខ្ញុំមិនគិតថាខ្លួនឯងមានសមត្ថភាពខ្លាំងក្នុងការទាក់ទាញមនុស្សស្រីទេ អាចនិយាយថា ខ្ញុំស្អប់មនុស្សមានមោទនភាពជ្រុល តែខ្ញុំក៏មានទំនុកចិត្តថា ខ្ញុំមិនពិបាកដូចគេ ក្នុងការរកបានសង្សារស្អាតៗជាបន្តបន្ទាប់ដែរ។

ម្ដងណោះខ្ញុំងាកខ្វាច់ទៅឱ្យចាប់នាងបានតែម្ដង។

នាងគេចភ្នែកមិនទាន់ទេ ក៏សម្លឹងខ្ញុំភាំង។

ខ្ញុំញញឹមដាក់ស្រីស្អាតមាត់រឹងម្នាក់នេះ ព្រោះមិនចង់ធ្វើជាមនុស្សឆ្មើងឆ្មៃ។ អំនួតមិនមែនជាស្ទីលឬផ្នែកអាក្រក់ក្នុងចរិតលក្ខណៈខ្ញុំទេ តែ«មានៈ»វិញអាចថា មានច្រើនគួរសមដែរ។

ជាពិសេសម្នាក់ស្រីដែលពូកែលបមើលខ្ញុំបែប«Sad Sad» ។

«ទៅទិញកាហ្វេឥឡូវហើយ! យកដែរ? ចាំទិញផ្ញើ!»

ខ្ញុំនិយាយនេះ ព្រោះមកឈរជ្រែងលេងរាងសង្ហានៅមុខគេ និងពិនិត្យឃើញកែវកាហ្វេទទេរបស់គេសល់ពីព្រឹកនៅលើតុនៅឡើយ។ ម៉ានីមិនអាចនិយាយបដិសេធថា មិនចេះញ៉ាំកាហ្វេដូចសុជាតាទេ។

«ហេតុអ្វី?»នាងសួរមកវិញទាំងសម្លឹងមុខខ្ញុំដោយមិនញញឹម។

«អរគុណ!»

«រឿងអី?!»នាងសួរទៀតដូចចង់លេងសម្ដីនឹងខ្ញុំជានិច្ច។

ខ្ញុំឱនទៅខ្សឹបៈ

«អរគុណខ្សែភ្នែក!»

នាងបង្ហាញភាពឆ្ងល់ហើយមិនសម្លឹងខ្ញុំទៀតទេ។ នាងខ្លាចខ្ញុំឃើញចិត្តពិតរបស់នាងដឹង?ខ្លាចអីទៅ? ខ្ញុំមិនមែនយក្សាឯណា?

«ឱ្យខ្សែភ្នែកមកបញ្ជាក់ថាយកចិត្តទុកដាក់!» ខ្ញុំនិយាយចែចង់ទាំងមានទំនុកចិត្ត។

«ឈ្លក់វង្វេងនឹងខ្លួនឯង» នាងថារអ៊ូតិចៗបន្តការងារលើកំព្យូទ័រដូចចង់ដេញខ្ញុំចេញ។ ខ្ញុំមិនព្រមចេញ នៅតែបន្តខ្សឹបៈ

«ឈ្លក់វង្វេងនឹងខ្លួនឯងគ្រាន់បើជាងកុហកខ្លួនឯង!»

នាងតវ៉ាមកវិញៈ

«មានអីខុសគ្នា?»

«ហោចណាស់ខ្ញុំហ៊ានញ៉ែមនុស្សដែលខ្ញុំចាប់ចិត្ត!»

«នៅឯណា? ហើយនេះម៉ោងធ្វើការ!» គេនៅតែថាមក រួចមិនចាញ់ខ្ញុំហើយនឹងមានមាត់រឹងមិនសារភាពទេ។ ខ្ញុំចង្អុលទៅគេតិចៗមុនពេលចាកចេញហើយខ្ញុំផ្ញើទុកស្នាមញញឹមគុំគួនថានឹងតាមគេឱ្យបាន ផ្ញើនៅទីនេះជាមួយគេ។

«អ៊ើ! ខ្ញុំអត់ញ៉ាំកាហ្វេតែខ្ញុំចេះញ៉ាំGreen Tea»

ជាឆាតសម្រាប់យប់នេះ។ តែកុំច្រលំណា៎ មិនមែនម៉ានីទេ គឺអាតាបុគ្គលិកចូលថ្មី។ នាងនៅកន្លែងធ្វើការនឹងនរមែន មិនឆ្លើយមិនឆ្លងទោះមានអ្នកអុកឡុកច្រើនតែយប់នេះនាងស្គាល់ទាំងឆាតខ្ញុំហើយសរសេរមកថ្មើរណេះ?

ចាំអង្គាល់?

ឱកាសយកជ័យលើកម្លោះៗផ្សេងៗទៀតត្រូវបានបង្ហាញមកដល់នឹងមុខខ្ញុំ។ ប្រហែលជាខ្ញុំអាចចិត្តងាយ ពេលដែលមានមនុស្សស្រីស្អាតៗសារភាពថាគេពិតជាទាក់ទាញចិត្តនឹងខ្ញុំហើយនេះជារឿងដែលខ្ញុំចូលចិត្ត ព្រោះមនុស្ស«កុហកខ្លួនឯង»ដូចម៉ានី វិញបុរាណពេកណាស់សម្រាប់ខ្ញុំ។

មិនយូរទេ សម្រាប់កសាងចំណងទាក់ទងគ្នារវាងតានិងខ្ញុំ។ យើងទៅញ៉ាំកាហ្វេជាមួយគ្នាញឹកញាប់រហូតដល់គ្រប់គ្នាដឹង នឹងខ្សឹបខ្សៀវរឿងយើង។ ប្រុសៗផ្សេងៗក៏ឈប់មករវៀរវៀរនៅមុខតុនាងទៀតដែរ។

ដូចសង្សារគេដទៃដែរ ខ្ញុំតែងព្យាយាមធ្វើឱ្យតាមានអារម្មណ៍ពិសេស ខ្ញុំផ្ញើសារទៅគេញឹកញាប់ហើយថែមទាំងនិយាយអំពីពាក្យល្អៗកំដរអារម្មណ៍គេយ៉ាងផ្អែមល្ហែម។ គេវិញ ពិតជាមានមនោសញ្ចេតនាជ្រៅឡើងៗនឹងទំនាក់ទំនងរបស់យើង ថែមទាំងបដិសេធមិនព្រមដើរលេងជាមួយមិត្តភ័ក្តិណាទាំងអស់  ចំណាយពេលដែលសម្រាក តែជាមួយខ្ញុំ ។

យើងជាគូស្នេហ៍ដែលញញឹមអង្គុយក្នុងហាងកាហ្វេ ហើយនិយាយគ្នាមិនចេះចប់ពីរឿងមួយទៅរឿងមួយ។

«ម៉ាក់ខ្ញុំចង់ឃើញណោង!»

នាងនិយាយពាក្យនេះ ក្រោយយើងស្គាល់គ្នាទើបតែបានប្រហែលជា៨អាទិត្យ បានន័យថា តាពិតជាកំពុងជឿជាក់ថា ដើរលើផ្លូវត្រូវជាមួយខ្ញុំក្នុងការកសាងស្នេហាពិត។

ចំណែកខ្ញុំឯណេះវិញលេចចេញសញ្ញាសួរនៅពីលើក្បាលឡើងធ្ងន់។ តាមពិត ខ្ញុំបានធ្វើរឿងទាំងអស់សមជាមិត្តប្រុសRomantic ម្នាក់សម្រាប់តា តែខ្ញុំមិនដែលបានត្រៀមខ្លួនរួចជាស្រេចឬមានការប្ដេជ្ញាចិត្តយ៉ាងពេញលេញចំពោះស្នេហានេះជាអនាគតវែងឆ្ងាយនៅឡើយ។

«ពេលណា? ឱកាសអីទៅ? នៅរវល់បន្តិច!»

ខ្ញុំឆ្លើយបែបនេះគេអន់ចិត្តជាខ្លាំង។

ភ្លាមនោះខ្ញុំក្រឡេកគេចចេញពីកែវភ្នែករបស់ត វាក់អើនឹងភ្នែកស្រពោនរបស់ម៉ានីដែលមិនដឹងជាសម្លឹងមកខ្ញុំតាំងពីពេលណា។ គេកំពុងឈរទិញកាហ្វេ គេឃើញខ្ញុំនឹងតា ហើយលបសម្លឹងមកខ្ញុំទៀត។

គេគេចចេញវិញភ្លាមដោយធ្វើមិនដឹងពេលខ្ញុំឃើញគេ។

ខ្ញុំនឹងតាមិននិយាយអ្វីបានទៀតទេពេលនេះ តាអន់ចិត្ត ឯខ្ញុំវិញក្នុងអំឡុងយប់នោះឱប សំណួរតែមួយគត់គឺ ហេតុអ្វី?

ហេតុអ្វីបានជាខ្ញុំចង់តែ ដកខ្លួនចេញពីចំណងជាមួយតា និងដូចជា ផ្លាស់ប្តូរចិត្តភ្លាមៗ ហើយឈប់ខិតខំប្រឹងប្រែងយកចិត្តគេ  ក្រោយពេលឃើញម៉ានី?

សំខាន់បំផុត ហេតុអីនាងនៅតែមើលមកខ្ញុំរបៀបនោះ? សំណួរសាំញ៉ាំទាំងនេះបានរត់ច្របល់ពេញក្បាលប៉ុន្តែមិនមានចម្លើយទេ។

បន្ទាប់មកខ្ញុំ ដឹងថា ខ្ញុំមិនសូវគិតពីរឿងខ្លាចបែកបាក់ជាមួយតាទេ ប្រហែលខ្ញុំតែងតែមានលទ្ធផលបែបនេះជាមួយនឹងអ្នកមុនៗ?

តានៅតែធ្វើដដែលរបៀបជាសង្សារតែគ្រប់យ៉ាងពេលនេះគឺខ្ញុំរសាយចិត្តលែងចង់ពាក់ព័ន្ធនឹងនាងទៀតទាំងមិនដឹងមូលហេតុ។ ជាមួយនឹងកម្រិតនៃការគោរពខ្លួនឯងក៏ដូចជាភាពស្មោះត្រង់ដែលតែងតែប្រកាន់យកមករហូតនោះ ខ្ញុំមិនចង់ធ្វើពុតទេ។

ខ្ញុំពិតជាមិនបានជួបអ្នកណាផ្សេងថែមទាំង មិនមាន ហេតុផលត្រឹមត្រូវសម្រាប់ការបែកបាក់ដែលទាមទាររុកកួន នៅក្នុងក្បាលរាល់យប់ តែខ្ញុំពិតជាចង់បែកគ្នាជាមួយនាង។

«វាជារោគសញ្ញាច្របូកច្របល់» បញ្ញាជួយគិតខ្ញុំពេលខ្ញុំនិយាយប្រាប់គេហើយគេយល់ថាខ្ញុំនេះកំពុងទទួលរងនូវរោគសញ្ញាច្រលំចិត្តខ្លួន ឯង ដោយសារតែភ័យខ្លាចខាងស្រីជំរុញឱ្យរៀបការ។

«បើច្របូកច្របល់ដូចឯងថាមែន មិនមែនរឿងរៀបការទេ អញប្រហែលស្រលាញ់អ្នកផ្សេង!»

«អ្នកណា? ក៏....ចិត្តរាយមាយម៉េះអាណោង? »

បញ្ញាបន្ទោសខ្ញុំ ។ ខ្ញុំក៏ដឹងដែរថាខ្លួនឯងបានក្លាយជាកំពូលមនុស្សច្របូកច្របល់ ដែលមិនមានពេលសម្រាប់មើលឃើញតម្លៃនៃចិត្តស្នេហារបស់តាទេ។

ទស្សនៈនិងអារម្មណ៍របស់ខ្ញុំលើគេ( សុជាតា )បានផ្លាស់ប្តូរយ៉ាងខ្លាំង ហើយមិនដឹងហេតុអ្វីខ្ញុំតែងគិតនិងចង់ដឹងថា ម៉ានីកំពុងធ្វើអ្វី នាងមានសង្សារឬនៅ? តែខ្ញុំមិនដែលនិយាយរឿងនេះប្រាប់បញ្ញាទេព្រោះមិនដឹងថា ត្រូវធ្វើ ឬនិយាយ ឬចាប់ផ្តើមពីណា។

ទេ មែនទេ?

តមកនេះ ខ្ញុំអង្គុយសំកុកក្នុងការិយាល័យដោយមានការព្រួយបារម្ភ ពីររឿងគឺមិនយល់គំនិតខ្លួនឯងដែលរក្សាការនឹករលឹកម៉ានី និងចិត្តមួយទៀតចង់តែគេចៗពីអាតាទាំងមិនទាន់បាននិយាយគ្នាដាច់ស្រេចសោះ។

នាងគ្មានកំហុសទេ ខ្ញុំជាអ្នកខុស។

ដល់យប់មួយដែលគ្រប់គ្នាសប្បាយរីករាយតុបតែងខ្លួនស្អាតបាត គឺមានកម្មវិធីជប់លៀងនៅកន្លែងធ្វើការ។ រាល់ពេលខ្ញុំតុបតែងនឹងសម្លឹងខ្លួនខ្ញុំក្នុងកញ្ចក់ ម្តេចខ្ញុំតែងលបគិតថា តើម៉ានីចង់ឃើញខ្ញុំក្នុងរូបរាងរបៀបនេះដែរទេ? ខ្ញុំមិនបានគិតពីអាតាទេ។

ពាក្យមួយគេនិយាយថា បុរសដូចយើងច្រើនលង់ស្នេហ៍នឹងមនុស្សស្រី ណាដែលនាងព្រមទទួលយកយើងជាយើង ទាំងផ្នែកល្អនិងមិនល្អ  ហើយយល់ពីយើងដែរ។ តែម៉ានីវិញ មួយម៉ាត់ក៏មិនដែលបង្ហើបទាក់ទងនឹងរឿងខាងលើឯណា ឬមួយខ្សែភ្នែកនាង ដែលលួចសម្លឹងមកខ្ញុំម្តងៗ ពិតជាមានអត្ថន័យដល់រាប់សែនពាក្យ?

«អញចង់រាំជាមួយម៉ានី!»

មិនមែនខ្ញុំនិយាយទេគឺបញ្ញានិយាយប្រាប់ខ្ញុំ។ ខ្ញុំបែរខ្នងដាក់វាលួចលើកស្រាអក ឯចិត្តខ្ញុំរោលរាលប្រចណ្ឌនិងច្រណែនគ្មានដំណើរដើមទង។

វាតែងតែមានហេតុផលសម្រាប់រាល់សកម្មភាពដែលយើងចង់ធ្វើ តែឥឡូវនេះខ្ញុំមិនមានហេតុផលច្បាស់ថា ហេតុអ្វីបានជាឃើញអាតាខ្ញុំចង់តែរត់ ឃើញម៉ានីខ្ញុំចង់តែចូលទៅរកនាង?

សភាពខ្លាចអារម្មណ៍ខ្លួនឯងបានធ្វើឱ្យខ្ញុំស្រងូតព្រួយបារម្ភម្នាក់ឯងកណ្តាលភាពអឺកអធឹក។ នៅពេលដែលយើងមិនអាចដកយករូបភាពនារីម្នាក់ចេញពីចិត្តរបស់យើងបាន ទាល់តែសោះនោះជាសញ្ញាអាសន្នហើយ ។ ទោះបីជាខ្ញុំព្យាយាមយ៉ាងណាក៏ដោយ ម៉ានីតែងតែនៅទីនេះក្នុងគំនិតរបស់ខ្ញុំ។ គ្រប់យ៉ាងអំពីបេះដូងខ្ញុំអារម្មណ៍ខ្ញុំ ក្លាយជាគ្មាននរណាម្នាក់អាចបំពេញបានក្រៅតែពីឈ្មោះនាងរូបភាពនាង តាមរបៀបមួយដែលមិនអាចពន្យល់បានងាយទេ។

ខ្ញុំមិនចង់មើលទៅគេរាំជាមួយបញ្ញាទេស្រាប់តែ ខ្ញុំក្រឡេកទៅដោយឥតព្រាងទុកក៏ឃើញគេមើលមកខ្ញុំទៀត។

អស្ចារ្យហើយ!

ខ្ញុំមិនបាននៅក្បែរអាតាទៀតទេតាំងពីមកដល់ពីធី ចំណែកអាតាក៏នាងទំនងដឹងពីអារម្មណ៍«បែកគ្នា»រវាងពួកយើងដែរ។

ខ្ញុំសរសៀរទៅរកម៉ានីទៀតទោះហាមខ្លួនឯងយ៉ាងណាក៏ដោយ។

«តោះ! រាំហ្អី?»

ស្មានមិនដល់ថា អ្នកដែលឡើងរាំជាមួយគេមិនមែនបញ្ញាគឺខ្ញុំ។

ឥឡូវនេះ ដៃខ្ញុំនៅលើចង្កេះគេហើយ ចំណែកគ្រប់គ្នាក៏កំពុងមើលពីរនាក់យើងដែរដូច្នេះខ្ញុំគ្មានពេលគិតថា បញ្ញាខឹងឬអាតាអាម៉ាស់មុខទេ។ ចិត្តខ្ញុំផ្តោតតែលើម៉ានីម្នាក់គត់ពេលនេះវិនាទីនេះ។

ពេលកំពុងរាំខ្ញុំបានឱកាសនិយាយនឹងនាងភ្លាមថា៖

«អានីឯងតាមពិតចូលចិត្តខ្ញុំ តែអានីមិនដឹងចិត្តខ្លួនឯង!»

«ប្រសិនបើខ្ញុំមិនដឹង បានន័យថាខ្ញុំមិនបានចូលចិត្តណោងឯងទេ!» នាងតមកទាំងកំពុងសិតក្នុងទ្រូងខ្ញុំ។

«ខ្ញុំលង់ស្រលាញ់ស្រីមាត់រឹងហើយ!»

នាងញញឹមតិចៗចំអកឱ្យខ្ញុំ តែខ្ញុំនៅលង់តែជាមួយខ្សែភ្នែករបស់នាង។

«ចុះអាតា?»

គេសួរមកខ្លីមែនក៏ប៉ុន្តែត្រូវចិត្តខ្ញុំណាស់។ បានន័យថា ម៉ានីបានតាមដានខ្ញុំយូរហើយ គេអាចប្រចណ្ឌហួងហែងទៀត?

«អាតាល្អណាស់តែខ្ញុំចង់ នៅជាមួយមនុស្សស្រីដែលខ្ញុំចូលចិត្ត១០០% !»

«មិនចេះខ្មាស់! គ្មានការទទួលខុសត្រូវ!»

គេថាឱ្យខ្ញុំទាំងមុខក្រញូវ តែខ្ញុំនៅតែមិនញញឹមតបតវិញទៅកាន់គេ៖

«ខ្ញុំទទួលខុសត្រូវគ្រប់ពាក្យដែលខ្ញុំកំពុងនិយាយជាមួយអានីយប់នេះ! ចេញពីនេះទៅវគ្គពីរជាមួយគ្នាបានអត់?»

ខ្ញុំស្ទើទ្បើងដោយមិនទាក់ទើរនេះ ព្រោះប្រាកដថា គេក៏ចូលចិត្តខ្ញុំ គិតពីខ្ញុំដូចគ្នា ប៉ុន្តែម៉ានីបែរជាញញឹមទៀតមុនពេលឆ្លើយ៖

« ឆ្ងល់អត់ដែលណោងឯងចេះនិយាយពាក្យនេះចេញរួច»

«មានអីឆ្ងល់? មានអ្វីខុស? ខ្ញុំគ្រាន់តែស្រលាញ់ម៉ានី!ហើយ....»

«គួរឱ្យអស់សំណើចអត់ដែលខ្ញុំប្រាប់វិញថាមិនបានចាប់អារម្មណ៍ ? កុំថាស្រលាញ់សូម្បីរាប់អានក៏គ្មាន...»

កំប្លែងបំផុត និងគួរឱ្យចុកចាប់ក្នុងអារម្មណ៍បំផុតដែរ ដែលមកត្រូវនាងបដិសេធរបៀបនេះ។

គ្មាននរណាម្នាក់ចូលចិត្តការបដិសេធទេ តែខ្ញុំមិនបានខឹងនាង....ថែមទាំងព្យាយាមសួរ៖

«ហេតុអ្វីបានជាចូលចិត្តបដិសេធអារម្មណ៍ខ្លួនឯង? បានការអីទៅធ្វើអីចឹងនោះ?»

«អារម្មណ៍ខ្ញុំមានទាក់ទងអីនឹងណោងឯង? ហើយណោងឯងក្លាយជាអ្នកស្គាល់អារម្មណ៍ខ្ញុំតាំងពីពេលណាមក?»

ខ្ញុំនៅតែប្រាប់ខ្លួនឯងថា ការបដិសេធនេះមកពីពេលវេលាមិនត្រឹមត្រូវឬហេតុផល ផ្សេងៗទៀតឬមកពីខ្ញុំនៅមានអាតា។

«ខ្ញុំមានគម្រោងសុំបែកអាតា!»

ខ្ញុំសារភាពប្រាប់គេទាំងស្រវឹងតិចៗ។ គេហាក់សប្បាយចិត្ត។

«ល្អណាស់!»

ម៉ានីនិយាយខ្លីត្រឹមពីរម៉ាត់នេះ ឯខ្ញុំមិុចភ្នែកតាមសម្គាល់ឬកពាររត្រេកអររបស់នាង។ មិនចង់ឆ្ងល់យូរទេខ្ញុំពោលសួរនាងឡើងភ្លាមថា៖

«បើមិនស្រលាញ់ខ្ញុំអរម៉េះពេលខ្ញុំបែកសង្សារ!»

«ព្រោះខ្ញុំស្រលាញ់គេ!អាតា!»

ខ្ញុំភាំង។

តែអ្វីមួយក្នុងពេលនេះខ្សឹបប្រាប់ខ្ញុំថា សម្ដីនាងអាចជាអ្វីមួយមានន័យពិតបើតាមភ្នែកនាងដែលបញ្ជាក់មកខ្ញុំច្បាស់ៗ។

«កំប្លែង!»ខ្ញុំធ្វើជាសើចបន្លប់ហើយនិយាយបន្ថែមៈ«ប្រហែលជាម៉ានីមិនទាន់បានត្រៀមខ្លួនស្រេចបាច់និងខ្លាចអ្នកផងគិតថាជាអ្នកទីបី?»

«មនុស្សខ្ញុំមិនដែលខ្លាចអ្នកណានិយាយទេ!»

នាងតបមកដោយតឹងរឹង។ កាយវិការម៉ានីចាប់ផ្ដើមរឹងៗ ហើយមានទឹកមុខព្រមជាមួយកែវភ្នែករឹងមាំដូចជាមនុស្សប្រុស។ ទោះបីនាងតែងតែមានការរស់នៅរបៀបរបរតុបតែងក្នុងសភាពជាមនុស្សស្រីហេតុអ្វីពេលនេះម៉ោងនេះខ្ញុំបែរជារកឃើញភាពជាមនុស្សប្រុសក្នុងខ្លួននាង?

រឿងកាន់តែសាមញ្ញ ឡើងនៅពេលនាងប្រាប់ថា នាងតាមមើលខ្ញុំព្រោះនាងចង់ធ្វើចរិតឬកពារដូចខ្ញុំ តែមិនមែនស្រលាញ់ខ្ញុំទេ។

នាងជាស្រីស្រលាញ់ស្រីដូចគ្នា។

«មិនត្រឹមតែមានគំនិតបុរាណ ណេងឯងមានជំនឿខ្លាំងលើខ្លួនឯងពេកដឹង? ហើយយកការគិតស្រមៃរបស់ណេងឯង ទៅវិនិច្ឆ័យថា ជាការពិត?»

ពិតជាខូចចិត្តនិងអៀនខ្មាស់ ។ ក្រោយមកខ្ញុំអានប៉ះសៀវភៅមួយដែលអ្នកចិត្តសាស្ត្របានរកឃើញមាត្រដ្ឋានពីរមានឥទ្ធិពលលើ ទំនាក់ទំនងស្នេហារបស់មនុស្សយើង។

ទីមួយ យើងឱ្យសារៈសំខាន់ លើចំណាប់អារម្មណ៍ដំបូង និងសញ្ញាដំបូងនៃភាពឆក់គ្នា រវាងភ្នែកនិងអារម្មណ៍ផ្ទាល់ខ្លួនដែល គេហៅថាទ្រឹស្ដីទំនាក់ទំនងមិនច្បាស់លាស់បង្កើតការឈឺចាប់និងភាន់ច្រលំជាច្រើន។

ទីពីរមនុស្សយើង មានធម្មជាតិចាប់អារម្មណ៍ខ្លាំងពេកពីភាពខុសគ្នានៃអាកប្បកិរិយាដែលមិនច្បាស់លាស់ ។

ការចង់ដឹង ការឆ្ងល់ហួសហេតុ ថាមនុស្សម្នាក់នោះកំពុងគិតអ្វីពីយើង ក៏អាចធ្វើឱ្យយើងច្រលំ និងពង្វក់ខ្លួនឯងទៅរកការលង់ចិត្តលើគេបានដែរ។

សម្រាប់ខ្ញុំ ខ្ញុំយល់ថា នោះជាពេលវេលាមួយក្នុងជីវិតដែលខ្ញុំបានឆ្កួតចិត្តព្រោះ«ខ្សែភ្នែក»មួយ ដែលមិនមានអត្ថន័យដូចខ្ញុំគិតសោះ បែរជាខ្ញុំយកមកពង្វក់អារម្មណ៍ខ្លួនឯងជ្រៅឡើងៗ។

-----

សួស្តី! រឿងខ្លីមួយនេះ អ្នកនិពន្ធបានព្យាយាមសរសេរចេញពីបទពិសោធន៍ពិតរបស់នៃហ្វេនម្នាក់! អរគុណដែលផ្តល់នូវសាច់រឿងពិតមកជាទុនបង្កើតឡើងនូវសំណៅរឿងខ្លីប្លែកមួយសម្រាប់យុវវ័យពិចារណា។

សូមជូនពរគ្រប់គ្នាដែលបានអាន អាចរកបានស្នេហាស្មោះស្ម័គ្រនឹងគ្នារហូតរៀងទៅ។